**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា៥ មាត្រា៧ មាត្រា១២ មាត្រា១៧ នៃអនុក្រឹត្យលេខ ២១អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ និង មាត្រា៦ថ្មី នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល

✵✵✵✵✵✵✵✵✵✵✵

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រម លេខ នស/រកម០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រម លេខ នស/រកម/១១១៦/០១៤ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ៦៧អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ. បក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០០៧ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល

www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា ៦នៃអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រាមួយ.-**

មាត្រា៥ មាត្រា៧ មាត្រា១២ មាត្រា១៧ នៃអនុក្រឹត្យលេខ ២១អនក្រ.បក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល និងមាត្រា៦ថ្មីនៃអនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា៦ នៃអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាលត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា៥ ថ្មី.-**

ចំនួននិស្សិតដែលត្រូវជ្រើសរើសចូលរៀនតាមមុខជំនាញ ព្រមទាំងសូចនាករអនុវត្តន៍សម្រាប់លក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យ ដែលចែងក្នុងមាត្រា៣ នៃអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០១៦ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

ការបែងចែងកូតាសម្រាប់ការប្រឡងជ្រើសរើសចូលរៀនថ្នាក់ជាតិក្នុងវិស័យសុខាភិបាលត្រូវអនុវត្តត្រឹមឆ្នាំសិក្សា២០១៨-២០១៩។

**មាត្រា៦ ថ្មី.-**

ការចូលរៀន និងការប្រឡងបញ្ចប់ការសិក្សានៅគ្រប់កម្រិត និងគ្រប់ជំនាញ ក្នុងវិស័យសុខាភិបាល ត្រូវមានការប្រឡងថ្នាក់ជាតិ។ បេក្ខជនត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទើបអាចប្រឡងចូលរៀនថ្នាក់ឆ្នាំទី១សម្រាប់កម្រិតមធ្យម និងថ្នាក់ឆ្នាំសិក្សាមូលដ្ឋានសម្រាប់កម្រិតឧត្តម។ ចំពោះកម្រិត និងជំនាញសុខាភិបាលផ្សេងទៀតត្រូវគោរពតាមលក្ខខណ្ឌរបស់ក្រសួងសុខាភិបាល។ ការប្រឡងថ្នាក់ជាតិដើម្បីទទួលស្គាល់គុណវុឌ្ឍិអ្នកបញ្ចប់ការសិក្សាគ្រប់កម្រិត គ្រប់ជំនាញ ត្រូវធ្វើឡើងបន្ទាប់ពីការប្រឡងបញ្ចប់ការសិក្សាដោយជោគជ័យពីគ្រឹះស្ថានបណ្តុះបណ្តាល។

**មាត្រា៧ ថ្មី.-**

គណៈកម្មាធិការប្រឡងថ្នាក់ជាតិ ត្រូវតែងតាំងឡើងដោយរាជរដ្ឋាភិបាល ដែលមានសមាសភាពដូចខាងក្រោម៖

- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី ប្រធាន
- រដ្ឋលេខាធិការក្រសួងសុខាភិបាលទទួលបន្ទុកការងារបណ្ដុះបណ្ដាល អនុប្រធាន
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡាទទួលបន្ទុកឧត្ដមសិក្សា អនុប្រធាន
- អគ្គលេខាធិការនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា សមាជិក
- សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ ឬនាយកគ្រឹះស្ថានសិក្សាសាមី សមាជិក
- តំណាងគណៈវិជ្ជាជីវៈពាក់ព័ន្ធ សមាជិក
- ប្រធានក្រុមប្រឹក្សាសាកលវិទ្យាធិការកម្ពុជា សមាជិក
- ប្រធានក្រុមប្រឹក្សាភិបាលសមាគមគ្រឹះស្ថានឧត្ដមសិក្សាកម្ពុជា សមាជិក

គណៈកម្មាធិការប្រឡងថ្នាក់ជាតិនេះមានលេខាធិការដ្ឋានមួយ ជាជំនួយការដែលមានសមាសភាពមកពីនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងសុខាភិបាល។

គណៈកម្មាធិការប្រឡងថ្នាក់ជាតិប្រើប្រាស់ថវិកា បានពីការបង់ថ្លៃរបស់បេក្ខជនសម្រាប់រៀបចំការប្រឡងថ្នាក់ជាតិតាមរយៈច្រកចេញចូលតែមួយរបស់ក្រសួងសុខាភិបាល។

**មាត្រា១២ ថ្មី.-**

លក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យស្ដីពីគន្លង និងកម្រិតមុខជំនាញនៃការបណ្ដុះបណ្ដាល និងលក្ខខណ្ឌ និងស្ដង់ដារអប្បបរមាសម្រាប់ការបណ្ដុះបណ្ដាលក្នុងវិស័យសុខាភិបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា១៧ ថ្មី.-**

ចំពោះកម្មវិធីសិក្សាជាតិដែលបានដាក់ឲ្យប្រើប្រាស់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡានាពេលកន្លងមក ត្រូវរក្សាទុកអនុវត្តដដែល ហើយក្នុងករណីមានការកែសម្រួលត្រូវចេញដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ ដោយឡែកកម្មវិធីសិក្សាជាតិថ្មីគ្រប់កម្រិត និងគ្រប់ជំនាញ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

ផ្អាកជាបណ្ដោះអាសន្នចំពោះការបើកគ្រឹះស្ថានបណ្ដុះបណ្ដាលក្នុងវិស័យសុខាភិបាលថ្មី ឬសាខាថ្មី រហូតមានការសម្រេចជាថ្មីរបស់រាជរដ្ឋាភិបាល។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

www.pheakdeylaw.com

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ គ្រប់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលទាំងអស់ ត្រូវអនុវត្តតាមអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** **រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ហង់ ជួន ណារ៉ុន** **ម៉ម ប៊ុនហេង**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ